# ទស្សនវិជ្ជាសង្គមខ្មែរតាមរយៈពិធីភ្ជុំបិណ្ឌនៅកម្ពុជា

*ដោយៈ លោក* **ឈុន ផាឡែន**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## ១.សេចក្តីផ្តើម

*ពិធីបុណ្យភ្ជុំបិណ្ឌគឺជាវិធីប្រពៃណីផ្លូវការសំខាន់មួយក្នុងចំណោមពិធីបុណ្យធំៗដទៃទៀតរបស់ប្រជាជាតិខ្មែរតាំងពីបុរាណរៀងមក។ ថ្វីត្បិតពិធីបុណ្យនេះមិនឃើញមានចែងច្បាស់ក្នុងគម្ពីរពុទ្ធសាសនាក៏ដោយ ក៏ពុទ្ធសាសនិកជនខ្មែរបានខំកែច្នៃរៀបចំពិធីបុណ្យភ្ជុំបិណ្ឌនេះឱ្យស្របតាមបែបបទនៃព្រះពុទ្ធនិយមផងដែរ។ ជាតិសាសន៍នានាដែលកាន់ពុទ្ធសាសនាដែរ គេមិនបានប្រារព្ធធ្វើពិធីបុណ្យភ្ជុំបិណ្ឌដូចខ្មែរឡើយ ប៉ុន្តែគេមានពិធីបុណ្យប្រពៃណីផ្សេងៗទៅវិញ[1] ។*

*តើពិធីបុណ្យភ្ជុំបិណ្ឌមានខ្លឹមសារយ៉ាងណា និងផ្តល់ផលប្រយោជន៍និងបញ្ហាប្រឈមដូចម្តេចខ្លះដល់សង្គមខ្មែរ?*

## ២. អត្ថន័យនៃ "ពិធីបុណ្យភ្ជុំបិណ្ឌ"

*យោងតាម វចនានុក្រមសម្តេចសង្ឃរាជជួន ណាត ពាក្យថា "ពិធី" មានន័យថា បែប វិធី ឬរបៀបធ្វើ, របៀបបំពេញកិច្ចការ។ ឯពាក្យថា "បុណ្យ" មានន័យថា គុណជាតិដែលជាគ្រឿងជម្រះកាយ វាចា ចិត្ត ឱ្យលុះក្នុងកុសលដែលជាអំពើល្អអាចនាំអ្នកមនុស្សទទួលបានសេចក្តីសុខចម្រើន។ ហេតុនេះ ពិធីបុណ្យ គឺជារបៀបរៀបចំ កាយ វាចា ចិត្ត ឱ្យបរិសុទ្ធ ស្អាត ល្អ ត្រឹមត្រូវ គួរជាទីស្រឡាញ់ ជាទីចង់បានរបស់មនុស្សក្នុងសង្គម ទៅតាមបែប ទម្រង់ការនានា។ ចំណែកពាក្យថា "ភ្ជុំ" មានន័យថា ការប្រមូលផ្តុំគ្នា ការធ្វើឲ្យជួបជុំគ្នា។ រីឯពាក្យ "បិណ្ឌ" មានន័យថា "ដុំ ឬ "ការប្រមូលឲ្យមូលឬពូនឲ្យជាដុំ" "ការចិញ្ចឹមជីវិត" [1]។ ដូច្នេះ យើងអាចកំណត់អត្ថន័យនៃ "ពិធីបុណ្យភ្ជុំបិណ្ឌ" បានថាជា"*

---

[1] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧*

វិធីជួបជុំជជែកពិភាក្សាគ្នាដើម្បីស្វែងយល់ដឹងអំពីវិធីរស់នៅ ឬវិធីចិញ្ចឹមជីវិត”[2] ។

តាមការនិយាយតៗគ្នាជាជរាបរៀងមកថា ពិធីបុណ្យភ្ជុំបិណ្ឌ គឺជាពិធីប្រជុំដុំបាយ ព្រោះគេយល់ថា ពាក្យបិណ្ឌ មានន័យថា ដុំបាយដែលគេបានទំនុកបំរុងសម្រាប់ប្រេត។ ពាក្យថា ប្រេត ឬ បេត គឺជាសត្វមួយពួកដែលកើតក្នុងអបាយភូមិ[ii] ឬអ្នកដែលធ្វើមរណកាលទៅកាន់បរលោកហើយ។ នៅរដូវបុណ្យភ្ជុំ គេតែងនាំគ្នាទៅបោះបាយបិណ្ឌនៅជុំវិញព្រះវិហារនៅក្នុងវត្តអារាមនានា។ គំនិតស្តីពីការប្រជុំដុំបាយនេះក៏ជាគំនិតមួយដែលសាមញ្ញ ប៉ុន្តែវាមានអត្ថន័យធំធេងនិងជ្រាលជ្រៅដែលបង្កប់នូវលក្ខណៈគ្រប់គ្រាន់នៃទស្សនវិជ្ជាខ្មែរ ដែលស្របនឹងសុភាសិតខ្មែរលើកឡើងថា ធ្វើស្រែនឹងទឹកធ្វើសឹកនឹងបាយ។ បាយជាអាហារប្រចាំថ្ងៃសម្រាប់ជនជាតិខ្មែរ គេអាចរស់នៅនិងប្រឈមមុខនឹងអ្វីសព្វបែបយ៉ាងក្នុងជីវិត គេត្រូវតែមានបាយគឺស្បៀងអាហារគ្រប់គ្រាន់សម្រាប់បរិភោគ។ ការជុំគ្នាបរិភោគបាយសាមគ្គីជារៀងរាល់ឆ្នាំ គឺជាឱកាសផ្លាស់ប្តូរគំនិតទស្សនៈ និងសម្តែងមនោសញ្ចេតនាសន្តោសគ្នាទៅវិញទៅមកដើម្បីស្វែករកជីវិតរស់នៅក្នុងសង្គមប្រកបដោយសុខដុមរមនាកាន់តែប្រសើរ[iii] ឡើង។យើងអាចនិយាយថា៖ “ពិធីបុណ្យភ្ជុំបិណ្ឌគឺជា វិធីជួបជុំជជែកពិភាក្សាគ្នាដើម្បីស្វែងយល់ដឹងអំពីគោលការណ៍ចិញ្ចឹមជីវិតឱ្យបានប្រសើរ”។ វាជាវិធីជួបជុំរវាងអ្នករស់និងខ្មោចប្រេត គឺជាពិធីជួបជុំរវាងមនុស្សនិងព្រលឹងខ្មោចញាតិសន្តានទាំងឡាយ ដែលបានចែកស្ថានទៅហើយ។ នៅក្នុងពិធីជួបជុំនោះ គេតែងជជែកពិភាក្សាគ្នា ដើម្បីរំលឹកពីមេរៀនស្តីអំពី កត្តាដែលនាំដល់សេចក្តីវិនាសអន្តរាយ និងកត្តាដែលនាំមកនូវមង្គលសិរីសួស្តី ក្នុងការរៀបចំដំណើរការចិញ្ចឹមជីវិតរស់នៅ ឱ្យបានទទួលនូវសេចក្តីសុខចំរើន។

## ៣.របៀបធ្វើពិធីបុណ្យភ្ជុំបិណ្ឌ

ខ្មែរប្រារព្ធធ្វើពិធីបុណ្យភ្ជុំបិណ្ឌនៅក្នុងវត្តអារាមពុទ្ធសាសនា ចាប់ពីថ្ងៃ១រោច ដល់ថ្ងៃ១៥រោច ខែភទ្របទ រៀងរាល់ឆ្នាំ។ ពីថ្ងៃ១រោច ដល់ថ្ងៃ១៤រោច ហៅថាថ្ងៃកាន់បិណ្ឌ ហើយថ្ងៃ១៥រោច ហៅថាថ្ងៃភ្ជុំបិណ្ឌ។ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះជារៀងរាល់ថ្ងៃ ពុទ្ធបរិស័ទក្មេងចាស់ប្រុសស្រី យាយតា ព្រឹទ្ធាចារ្យ នាំគ្នាទៅវត្ត ដើម្បីសំអាតទីអារាម សមាទានសីលប្រាំ[iv] ឬសីលប្រាំបី[v] និង ចម្រើនមេត្តាភាវនាធម៌ជាដើម។ គេនាំគ្នាងើបពីព្រលឹមដាំបាយសម្រាប់យកទៅវត្ត។ ពេលព្រឹកវេលាងងឹតដែលព្រះអាទិត្យមិន

[2] និយមន័យដែលត្រូវបានបង្កើតដោយយោងតាមអត្ថន័យនៃពាក្យនិងខ្លឹមសារនៃទស្សនវិជ្ជាសង្គម នាបច្ចុប្បន្ន។

ទាន់រះគេនាំគ្នាបោះបាយបិណ្ឌឱ្យពួកប្រេតនិង ស្តាប់បរាភវសូត្រ លុះថ្ងៃរះគេនាំយកបាយទៅ ដាក់បាត្រ(រាប់បាត្រ) រៀបចំចាត់ចែងចង្ហាន់ ម្ហូបអាហារ សម្ល បង្អែម ចង្អាប វេរប្រគេនព្រះសង្ឃ។ ក្រោយពេលព្រះសង្ឃឆាន់រួច គេនាំគ្នាទទួលទានបាយជុំគ្នាទៅតាមការចាត់ចែងរបស់វត្តនីមួយៗ។ គេបរិភោគបាយបាត្រ[vi] គឺគេមិនបរិភោគបាយបិណ្ឌទេ ព្រោះ “បាយបិណ្ឌ” សម្រាប់តែបោះឱ្យប្រេតស៊ីប៉ុណ្ណោះ។ គេជឿថា ប្រេត ស៊ីតែបាយបិណ្ឌ ឬចំណីណាដែលគេបោះគ្រវែងចោលទៅដីគឺវាមិនអាចស៊ីអ្វីដែលគេរៀបចំត្រឹមត្រូវល្អឡើយ។ការបោះបាយបិណ្ឌ(ការបោះដុំបាយ)ជាសកម្មភាពមួយដែលមិនទាន់មានឯកភាពគ្នានៅក្នុងសង្គមពុទ្ធសាសនិកទាំងស្រុងនៅឡើយដោយអ្នកខ្លះបានចាត់ទុកការបោះបាយបិណ្ឌជាកិច្ចដ៏សំខាន់មួយមិនអាចខានបាននៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌ ខណៈដែលអ្នកខ្លះបានអះអាងនិងរិះគន់ថា ការបោះបាយបិណ្ឌជាទង្វើមិនត្រឹមត្រូវ ព្រោះវាជាការខ្ជះខ្ជាយនិងគ្មានសណ្តាប់ធ្នាប់។ ពុទ្ធបរិស័ទខ្លះអះអាងថា ការបោះបាយបិណ្ឌជាការធ្វើមិនត្រឹមត្រូវតាមការបង្រៀនរបស់ព្រះពុទ្ធឡើយ។ ចំណែកខ្លះទៀតយល់ថា ការបោះបាយបិណ្ឌនៅជុំវិញព្រះវិហារ ប្រាកដជាបានផលទៅដល់សាច់ញាតិដែលស្លាប់។ គេជឿថាព្រលឹងវិញ្ញាណទាំងឡាយត្រូវបានគេដោះលែងពីឋាននរកឲ្យមកកាន់វត្តអារាមដើម្បីទទួលអាហារពីសាច់ញាតិនៅពេលមិនទាន់ឃើញពន្លឺថ្ងៃ ហើយប្រេតត្រូវត្រឡប់ទៅឋាននរកវិញនៅមុនពេលព្រះអាទិត្យរះ។ រនោចខែកទ្រុបទ ជាវេលាដែលព្រះចន្ទពុំសូវមានពន្លឺ ហើយចេះតែងងឹតទៅៗ ដែលយមរាជដោះលែងពួកប្រេតទាំងឡាយ ឱ្យមករស់នៅលាយឡំជាមួយមនុស្សចាំទទួលភោគផលដែលបងប្អូនញាតិផ្តល់ឱ្យ។ ក្នុងរយៈពេលចំនួន១៤ថ្ងៃពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗទាំងជិតឆ្ងាយបានបែងចែកវេនជាក្រុម ដើម្បីកាន់បិណ្ឌជាប្រចាំថ្ងៃ។ ក្នុងបិណ្ឌនីមួយៗ នៅពេលយប់ គេជួបជុំគ្នា នមស្ការព្រះរតនត្រ័យ[vii] សមាទានសីល[viii] និមន្តព្រះសង្ឃចម្រើនព្រះបរិត្ត[ix] សូត្រមង្គលសូត្រ និងសម្តែងធម៌ទេសនា ព្រមទាំងប្រគេននិងជូនភេសជ្ជៈចំពោះព្រះសង្ឃ និងចាស់ព្រឹទ្ធាចារ្យ។ លុះព្រឹកឡើង គេបោះបាយបិណ្ឌ[x] ស្តាប់បរាភវសូត្រ ប្រគេនយាគូ(បបរ) និងភត្តាហារ(ភោជនាអាហារ; អាហារទូទៅ) ដើម្បីឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធក្រុមគ្រួសារញាតិមិត្តរបស់គេដែលបានធ្វើមរណកាលហើយ។ នៅយប់ថ្ងៃ១៤រោច គេប្រារព្ធធ្វើពិធីដូចយប់ថ្ងៃកាន់បិណ្ឌពីមុនៗដែរ ប៉ុន្តែមានលក្ខណៈឱឡារិកជាង។ ឱកាសនេះប្រជាជននិយមធ្វើនំផ្សេងៗ ពិសេសនំអន្សម និងនំគមសម្រាប់ប្រគេនព្រះសង្ឃ សែនព្រេន និងជូនឪពុកម្តាយ ចាស់ទុំ ញាតិមិត្តរបស់គេ ក្នុងឱកាសថ្ងៃបុណ្យភ្ជុំបិណ្ឌមិនដែលអាក់ខាន។ លុះព្រឹកឡើងថ្ងៃ១៥រោច ដែលជាថ្ងៃភ្ជុំបិណ្ឌនេះ ពុទ្ធ

បរិស័ទគ្រប់វេនបិណ្ឌទាំង១៤ អញ្ជើញមកចូលរួមយ៉ាងកុះករ ប្រគេនចង្ហាន់ព្រះសង្ឃ និងបង្សុកូល[xi] ដូចថ្ងៃកាន់បិណ្ឌដែរ ប៉ុន្តែថ្ងៃនេះមានលក្ខណៈអធិកអធមជាងថ្ងៃកាន់បិណ្ឌកន្លងមក។ តាមទម្លាប់នៅពេលល្ងាចថ្ងៃ១៥រោច គ្រួសារនីមួយៗរៀបចំពិធីសែនព្រេនជូនជីដូនជីតារបស់ខ្លួន។ លុះព្រលឹមស្រាងៗ ថ្ងៃ១កើត ខែអស្សុជ គេរៀបចំនំ ចំណី ផ្លែឈើ គ្រឿងបរិក្ខា ធុត ទៀនធូបដាក់ក្នុងទូកសិប្បនិមិត្តដែលធ្វើអំពីស្រទបចេកបណ្តែតតាមទឹកដើម្បីជាកិច្ចជូនដំណើរដូនតាត្រឡប់ទៅឋាននរកជាលំនៅរបស់គាត់វិញ។

នៅរាល់ពេលដល់រដូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌម្តងៗ ពលរដ្ឋខ្មែរតែងស្កាត់ជួបគ្នាមិនដែលខាន បើមិនបានជួបគ្នាតាមវេនបិណ្ឌ ក៏ទៅជួបនៅថ្ងៃភ្ជុំដែរ។ បងប្អូនកូនចៅ សាច់ញាតិសន្តានទាំងអស់ ទោះនៅទីជិត ឬទីឆ្ងាយ តែងតែធ្វើដំណើរទៅជួបជុំឪពុកម្តាយ បងប្អូន នៅឯភូមិកំណើត និងជាពិសេសនៅឯវត្តអារាមណាមួយ។ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិក កម្មករ បានឈប់សម្រាកបីថ្ងៃ ដើម្បីងាយស្រួលចូលរួមក្នុងឱកាសពិធីបុណ្យភ្ជុំ។ ប្រជាពលរដ្ឋខ្មែរបានយកឱកាសនេះឧទ្ទិសកុសលជូនដល់ព្រលឹង(វិញ្ញាណខន្ធ)ញាតិទាំង៧សន្តានដែលស្លាប់ទៅ និងជួបជុំជជែកពិភាក្សាពីបញ្ហាជីវិត និងបរិភោគអាហារសាមគ្គីនៅក្នុងវត្តអារាម ឬនៅតាមផ្ទះណាមួយ។ ហេតុនេះទើបខ្មែរចាត់ទុកថា ភ្ជុំបិណ្ឌជាបុណ្យប្រពៃណីចម្បងមួយក្នុងចំណោមបុណ្យប្រពៃណីប្រចាំឆ្នាំផ្សេងរបស់ខ្លួន។ អ្នកខ្លះជឿយ៉ាងស៊ប់ ថា នៅរដូវបុណ្យភ្ជុំ ប្រសិនបើប្រេត មករកគ្រប់ចំនួន៧វត្តហើយ តែរកមិនឃើញកូនចៅបងប្អូនជាញាតិមិត្រខ្លួនទេ នោះពួកប្រេតទាំងនោះនឹងជេរប្រទេច ដាក់បណ្តាសាឲ្យអ្នកមានជីវិតទាំងនោះរងនូវក្តីវិនាសហិនហោច ព្រាត់ប្រាស់ជាមិនខាន។ ទោះបីជំនឿបែបនេះបានបាត់បង់ឥទ្ធិពលស្ទើរទាំងស្រុងក៏ដោយ ក៏ជនជាតិខ្មែរនៅតែស្កាត់ជួបគ្នានៅតាមវត្តអារាមតាមទម្លាប់ប្រពៃណីរៀងមកដដែល។

## ៤. ប្រវត្តិនៃពិធីបុណ្យភ្ជុំបិណ្ឌ

មុនពេលព្រាហ្មណ៍សាសនា និងពុទ្ធសាសនាចូលមកដល់ទឹកដីខ្មែរ ជនជាតិខ្មែរមានគោលជំនឿរបស់ខ្លួនអំពីជីវចលនិយមតាំងពីដើមដំបូងនៃប្រវត្តិកំណើតរដ្ឋមកម្ល៉េះ។ ជនជាតិខ្មែរតែងដាក់ចំណីអាហារសែនដល់ព្រលឹងអ្នកដែលស្លាប់ជារៀងរាល់ពេលទទួលទានអាហាររបស់ខ្លួនជាដរាប។ លើសពីនេះរៀងរាល់រដូវកាលក្នុងឆ្នាំនីមួយៗព្រឹទ្ធាចារ្យចាស់ទុំខ្មែរតែងដឹកនាំអ្នកភូមិធ្វើពិធីសែនព្រេនដល់ខ្មោច ដែលគេធ្វើឡើងសម្រាប់អ្នកដែលស្លាប់ក្នុងពេលថ្មីៗឬអស់កាលដ៏យូរមកហើយ។ ខ្មែរហៅថាពិធីប្រចាំឆ្នាំនេះថារដូវបុណ្យខ្មោច ឬពិធីបុណ្យសែនដូនតា គឺនៅចំពេលដែលយមបាលបើកទ្វារឋាន

នរក។ ទោះបីក្រោយមកទទួលឥទ្ធិពលលទ្ធិព្រាហ្មណ៍ និងពុទ្ធសាសានាមហាយាន ក៏ដោយខ្មែរមិនបោះបង់ចោលលទ្ធិដើមរបស់ខ្លួនដែរ។ យើងសង្កេតឃើញជនជាតិខ្មែរបន្តអនុវត្តជំនឿទាំងនោះលាយចម្រុះគ្នា ដូចជាពិធីសែនព្រេននៅទីវត្តអារាម តាមស្រែចម្ការ ផ្ទះសម្បែង ពិធីលៀងអារក្ស ពិធីបូជាសពដោយមានអាចារ្យភ្ជុកស្មៀកពាក់ស។ល។ ចំពោះឥទ្ធិពលលទ្ធិព្រាហ្មណ៍ ខ្មែរអនុវត្តជំនឿគឺភាគច្រើនធ្វើឡើងតាមរយៈការបង្កើតនិមិត្តសញ្ញាសម្រាប់តំណាងអង្គអាទិទេពណាមួយ ដូចជាការដាប់ឬស្សូនឡ្យថ្មធ្វើជាតំណាងឲ្យលិង្គព្រះឥសូរនិងយោនីព្រះនាងឧមាវតី ការវេចនំអន្សម(តំណាងសិវៈលិង្គ) និងនំគម(តំណាងឧមាយោនី) ជាដើម។ នៅសម័យក្រោយមកដោយសារឥទ្ធិពលពុទ្ធសាសនា អ្នកប្រាជ្ញខ្មែរដែលជាពុទ្ធសាសនិកបានខិតខំកែច្នៃរៀបចំពិធីបុណ្យសែនដូនតា ឱ្យទៅជា ពិធីបុណ្យភ្ជុំបិណ្ឌ ដើម្បីឱ្យស៊ីគ្នានឹងគោលជំនឿនៃព្រះពុទ្ធនិយមតាមបែបខ្មែរ។ ពួកគាត់បានលើកយកសាស្ត្រាដែលនិទានអំពីរឿងបែបទេវកថានានា ក្នុងគម្ពីរសុត្តបិដក(ព្រះសូត្រ) មកច្នៃប្រឌិតបញ្ចូលជាគតិយ៉ាងប៉ិនប្រសប់។ ទោះយ៉ាងនេះក្តី ក៏គេពុំដឹងឱ្យច្បាស់ ថា ពិធីបុណ្យភ្ជុំបិណ្ឌនេះ ផ្តើមឡើងដំបូងក្នុងរជ្ជកាលស្តេចអង្គណា ឬក្នុងពុទ្ធសករាជនិងគ្រឹស្តសករាជណាទេ។ ផ្អែកតាមសិលាចារិកឲ្យដឹងថា ព្រះបាទយសោវរ្ម័ន គ្រងរាជសម្បត្តិរវាង គ.ស. ៨៨៩ ដល់៩១០ ព្រះអង្គបានសាងអាវាសជាច្រើន ហើយទ្រង់តែងធ្វើពិធីបូជាបាយបិណ្ឌជារៀងរាល់ខែ ដើម្បីឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធអ្នកស្លាប់ក្នុងចម្បាំង និងចំពោះខ្មោចទាំងឡាយដែលគ្មានបងប្អូនគ្រួសារញាតិសន្តាន។ នៅរជ្ជកាលព្រះបាទអង្គដួង (គ.ស ១៨២៨–១៨៥៩) ក្នុងព្រះបរមរាជវាំងជារៀងរាល់ឆ្នាំចាប់ពីថ្ងៃ១រោចខែភទ្របទ ព្រះរាជាធ្វើពិធីកាន់បិណ្ឌ លុះថ្ងៃ១២រោច ខែភទ្របទ ព្រះរាជាចេញថ្វាយព្រះបិតរ [xii] ហើយនៅថ្ងៃ១៥រោច ខែភទ្របទ មានទេសនាគាថាពាន់ [xiii]។ ពិធីបុណ្យភ្ជុំបិណ្ឌ ប្រហែលមានដើមកំណើតតាំងពីសម័យអង្គរមកម៉្លេះ ហើយជនជាតិខ្មែរនាំគ្នាបន្តប្រារព្ធធ្វើជាប់រហូតមកសម័យបច្ចុប្បន្ន ។ លើកលែងតែរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ប៉ុណ្ណោះដែលមិនអនុញ្ញាតឱ្យមានពិធីបុណ្យភ្ជុំបិណ្ឌនេះ ព្រោះរបបនោះប្រកាន់ខ្ជាប់លទ្ធិកុម្មុនីស្ត ដែលមានទំនោរកែប្រែទម្លាប់ចាស់នៅក្រោមពាក្យថា ធ្វើបដិវត្តវប្បធម៌ បំបាត់កាកសំណល់វប្បធម៌ចាស់គំរិលជំនឿអរូបី ឱនថយមិនជឿនលឿន។

គោលគំនិតសំខាន់របស់ខ្មែរដើម ក៏ដូចគ្នានឹងទ្រឹស្តីពុទ្ធសាសនាដែរ គឺ អប់រំមនុស្សឱ្យមានហិរិ និងឱត្តប្បៈ។ ហិរិ-ឱត្តប្បៈ ជាធម៌តែងអាស្រ័យ នាំមនុស្សរស់នៅបានសេចក្តីសុខចំរើន។ ហិរិ គឺខ្មាសអំពើអាក្រក់ ខ្មាសទុច្ចរិត ខ្មាសបាប និងឱ្យមានឱត្តប្ប គឺខ្លាចបាប ខ្លាចទុច្ចរិត មិន

ហ៊ានធ្វើអំពើអាក្រក់, តក់ស្លុតជ្រេញរអាចំពោះបាប។ ការអប់រំ និង សិក្សា ឱ្យល្អដោយលើកយកសុខសួគ៌ និង នរកប្រេត មធ្យោបាយដំបូងក្នុងជំនឿសម្រាប់ឧបករណ៍វិភាគរកហេតុផលពិចារណាស្វែងរកសច្ចភាព និងតថភាពសង្គមជាក់ស្តែងបន្ទាប់មកគេនឹងប្រើឱកាសបន្ថយភាពល្ងង់ខ្លៅនិងជំនឿគ្មានហេតុផលបាន។ ហេតុនេះហើយបានជាអ្នកប្រាជ្ញខ្មែរ បានលើកយករឿងដែលទាក់ទងនឹងស្ថានភាពអ្នកដែលស្លាប់ចែកឋាន(ខ្មោចឬប្រេត) មកបង្ហាញ ដើម្បីទុកជាជំនួយដល់អ្នកនៅរស់បានពិចារណាពីអតីតកាល បច្ចុប្បន្នកាល និងវាសនាអនាគតកាលរបស់ខ្លួន។ លោកបានយកគម្ពីរ ឬសាស្ត្រាព្រះពុទ្ធសាសនាមួយចំនួន ដើម្បី កែច្នៃពី រដូវសែនដូនតាខ្មែរឱ្យទៅជា ពិធីបុណ្យភ្ជុំបិណ្ឌ ដូចជាគម្ពីរធម្មបទ គម្ពីរសាស្ត្រាវិជ្ជាធរជាដើម។

**៤.១. គម្ពីរធម្មបទ**

គម្ពីរធម្មបទ បានចែងថា មនុស្សដែលស្លាប់ទៅ អាចបដិសន្ធិនៅឋានសួគ៌ ឬ ឋាននរកទៅតាមផលកម្មដែលខ្លួនបានសាងកាលពីពេលរស់នៅ។ អ្នកសាងកុសលបានទៅកើតនៅឋានសួគ៌(ទេវលោក) ហៅថា ទេវតា តែងសោយនូវវត្ថុទិព្វ ទទួលបានសេចក្តីសុខគ្រប់ប្រការ។ អ្នកសាងអកុសលបានទៅកើតជាប្រេតនៅឋាននរកតែងទទួលរងទុក្ខលំបាកវេទនា ដោយការស្រេកឃ្លាននិងទារុណកម្ម ឥតស្រាកស្រាន្ត។ ពេលណាមនុស្សរវេរឧទ្ទិសផលទៅឲ្យ ពួកប្រេតនឹងអាចទទួលបានផលនោះ។

បុគ្គលទាំងឡាយ ធ្វើកាលកិរិយា លះលោកនេះទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិទាំងឡាយឧទ្ទិសឲ្យហើយអំពីលោកនេះ។ ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទាប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នេះដែរ។ ផ្លូវទឹក មានទន្លេ និងស្ទឹងជាដើមដ៏ពេញ រមែងញុំាងសាគរឲ្យពេញប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ។ បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះបានឲ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្រ ជាសំឡាញ់របស់អញ ដូច្នេះហើយ គួរឲ្យទក្ខិណាទាន ចំពោះប្រេតទាំងឡាយ។ ការយំសោកសៅ និងការខ្សឹកខ្សួលដទៃណា មិនមានប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ ដល់ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាង

នោះដដែល ឥតបានដឹង បានឮឡើយ។[3]ហេតុនេះទើបព្រះសង្ឃដែលជាសាវ័កព្រះពុទ្ធសមណៈគោត្តម និយមសូត្រធម៌ដារឧទ្ទិសចំណែកបុណ្យ ឈ្មោះ តិរោកុឌ្ឌសូត្រ[xiv] នៅក្នុងពិធីបុណ្យភ្ជុំបិណ្ឌ និងក្នុងពិធីទក្ខិណានុប្បទានផ្សេងៗ ដើម្បីអនុមោទនាដល់ពួកប្រេត រហូតមកដល់សព្វថ្ងៃ។

**៤.២.គម្ពីរសាស្ត្រាវិជ្ជាធរ**

គម្ពីរវិជ្ជាធរ "ឬពិទ្យាធរ" បង្ហាញថា ព្រះសង្ឃព្រះនាមព្រះឧបគុត្តត្ថេរ បាននាំយកបណ្តាំប្រេតពីឋាននរកមកប្រាប់ស្តេចថា បើមនុស្សធ្វើបុណ្យដាក់បិណ្ឌឧទ្ទិសកុសលឱ្យនោះពួកប្រេតនឹងអាចបានឆ្អែតស្កប់ស្កល់បាត់ទុក្ខវេទនា។ ព្រះរាជាសម័យអង្គរដែលគោរពព្រះពុទ្ធសាសនាបានស្គាល់ពីតម្រូវការចាំបាច់របស់ព្រះសង្ឃគឺបច្ច័យ៤មានសំលៀកបំពាក់ អាហារ ជំរក និងថ្នាំពេទ្យ។ ព្រះរាជាដឹងថានៅពេលដែលព្រះសង្ឃនិមន្តដើរបិណ្ឌបាត្រ ក្នុងរដូវវស្សាតែងជួបប្រទះនឹងភ្លៀងផ្គរ និងភក់ជ្រាំបង្ករភាពលំបាកយ៉ាងខ្លាំង។ ព្រះរាជាបានអំពាវនាវដល់ប្រជារាស្ត្រឲ្យផ្គត់ផ្គង់អាហារ និងសម្ភារៈចាំបាច់មូលដ្ឋាននានាដល់ព្រះសង្ឃក្នុងរដូវវស្សា។ និន្នាការនេះបានបង្កើតឲ្យមាន គម្ពីរវិជ្ជាធរ ដែលនិយាយអំពីពិធីបុណ្យភ្ជុំបិណ្ឌ។ ស្តេចក៏ធ្វើជាចុតហ្មាយផ្សព្វផ្សាយដល់ប្រជារាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីឲ្យធ្វើបុណ្យដាក់បិណ្ឌ ឬកាន់បិណ្ឌនៅក្នុង រដូវវស្សាដោយផ្តាំផ្ញើថា ឲ្យធ្វើចំនៅថ្ងៃ១រោច ខែភទ្របទរហូតដល់ ថ្ងៃ១៥រោច ខែភទ្របទ។ ដោយហេតុនេះហើយទើបមាន ពិធីបុណ្យភ្ជុំបិណ្ឌជាប្រពៃណីជាតិ តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ។

**៥. ទស្សនៈស្តីអំពីប្រេត**

យោងតាមគម្ពីរមិលិន្ទប្បញ្ហា នៃព្រះពុទ្ធសាសនាបានចែងថា មនុស្សដែលស្លាប់ទៅតែងទៅកើតទីផ្សេងៗតាមកម្មរបស់ខ្លួន។ អ្នកដែលក្លាយជាប្រេតអាស្រ័យមកពីអំពើបាបកម្ម ដែលខ្លួនបានសាងទុកមក។ មនុស្សប្រព្រឹត្តិអាក្រក់ ធ្វើតែបាបកម្ម លុះស្លាប់ទៅតែងតែកើតជាប្រេត។ ប្រេតមាន ៤ពួកគឺ៖ ១.ពួកប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម(ឧត្តូបជីវី), ២.ពួកប្រេតដែលស្គាល់តែទុក្ខវេទនាដោយការស្រេកឃ្លានជានិច្ច(ខុប្បបាសិក), ៣.ពួកប្រេតដែលភ្លើងឆេះជានិច្ច(និជ្ឈាមតណ្ហិក) ៤.ពួកប្រេតដែលចិញ្ចឹមជីវិតដោយផលទាន ដែលគេឧទ្ទិសឲ្យ (បរទត្តូបជីវី)។

គម្ពីរនេះញ្ញាក់ច្បាស់ថា បណ្តាពួកប្រេតទាំង៤ពួកនេះ មានតែពួកប្រេតទី៤ទេ ដែលគេវេរឧទ្ទិសជូនទៅហើយអាចទទួលយកបាន

[3] ពុទ្ធសាសនបណ្ឌិត្យ, *ព្រះត្រៃបិដក, សុត្តន្តបិដក, ភាគ៥២* - ពស.២៤៩៧, ទំព័រទី ១៤

ដូចជាពួកប្រេតជាញាតិ របស់ព្រះបាទពិម្ពិសារជារាជាសោយរាជនៅប្រទេសឥណ្ឌានាសម័យព្រះពុទ្ធសមណៈគោត្តមជាដើម។

ជំនឿអំពីប្រេតមានការពិបាកយល់និងស្មុគ្រស្មាញ សម្រាប់មនុស្សគ្រប់សម័យកាលពិសេសសម្រាប់មនុស្សម័យទំនើបខាងបច្ចេកទេសវិទ្យាសាស្ត្រ។ យោងតាមតថភាពសង្គមជាក់ស្តែង ប្រេត សំដៅលើមនុស្សដែលជួបប្រទះការលំបាកវេទនានិងគ្មានសេរីភាពក្នុងការរស់នៅ គឺជីវិតរស់នៅប្រៀបដូចជានៅក្នុងគុកដោយសារតែសាងនូវបាបកម្ម ឬចុះកិច្ចសន្យាស៊ីឈ្នួលធ្វើការងារឱ្យថៅកែ។ ខ្លះជាប់ទោស ព្រោះប្រព្រឹត្តខុសសុជីវធម៌ ខុសសីលធម៌ ខុសគុណធម៌ និងខុសគន្លងប្រពៃណីវប្បធម៌ និងច្បាប់សង្គមដែលនៅជាធរមាន។ នៅក្នុងគ្រប់សម័យកាលនៃរបបគ្រប់គ្រង មនុស្សជាតិត្រូវគេបែងចែកជា២ប្រភេទ គឺ អ្នកមាន និង អ្នកក្រ។ អ្នកមានគឺជាអ្នកដែលមានទ្រព្យសម្បត្តិដែលអាចបំពេញសេចក្តីត្រូវការនិងសេចក្តីប្រាថ្នារបស់ខ្លួនបាន រស់នៅក្នុងសេចក្តីសុខសប្បាយដែលប្រៀបដូចទេវតានៅឋានសួគ៌ ផ្ទុយទៅវិញអ្នកក្រគឺជាអ្នកខ្វះខាតទ្រព្យសម្បត្តិ ហើយរស់នៅជួបទុក្ខលំបាក ប្រៀបដូចប្រេតនៅឋាននរក។ អ្នកខ្លះជឿថា ជីវិតរស់នៅក្លាយជាអ្នកមានឬអ្នកក្រ គឺអស្រ័យដោយសារអានិសង្សនៃកុសលឬអកុសលដែលគេបានសាងពីជាតិមុន នៅខណៈដែលអ្នកខ្លះបដិសេធគំនិតនេះព្រោះគេយល់ថាក្លាយជាអ្នកមាន គឺមកពីគេខ្លាតពូកែធ្វើជំនួញរួមផ្សំបរិយាកាសសង្គមអនុគ្រោះអំណោយផលល្អហើយក្លាយជាអ្នកក្រដោយសារសេចក្តីល្ងង់ខ្លៅលប្រអូស មិនចេះក្បួនរកស៊ី ឬមកពីធ្វាក់ខ្លួនឈឺ ឬមកពីចោរកម្ម ឬមកពីសង្គមមិនទាន់មានលទ្ធភាពទប់ស្កាត់អំពើជិះជាន់ពុករលួយកេងប្រវញ្ចពីសំណាក់អ្នកមានអំណាចៗល។

ក្នុងប្រវត្តិសាស្ត្រ ប្រជារាស្ត្រខ្មែរភាគច្រើនដែលក្រីក្រ ធ្លាប់រស់នៅប្រកបដោយសេចក្តីទុក្ខវេទនាប្រៀបដូចសត្វនរកប្រេតឬសត្វតិរច្ឆានដូចច្នោះដែរ។ អ្នកខ្លះធ្លាក់ខ្លួនក្រីក្រហើយរងទុក្ខវេទនាដោយសារតែខ្លួនប្រព្រឹត្តល្មើសគោលការណ៍ដែលមានចែងក្នុងបរាភសូត្រដូចជាស្អប់បណ្ឌិតស្អប់បញ្ញវន្ត មិនរាប់រកញាតិសន្តានរបស់ខ្លួន មានអាហារឆ្ងាញ់លួចលាក់ស៊ីម្នាក់ឯងមិនចែករំលែកដល់អ្នកដទៃ មិនចិញ្ចឹមរក្សាមាតាបិតាដែលចាស់ជរា លួចឆក់ប្លន់កុហក់បោកប្រាស់អ្នកដទៃ ប្រព្រឹត្តអបាយមុខស្រី ស្រា ល្បែង លើកតំកើងអ្នកលេងខ្លះខ្លាយឥតព្រួយ ឥតគិតប្រឹងប្រែង មិនខ្នះខ្នែង ខ្ជិលច្រអូស ដេកច្រើន និយាយច្រើន ខឹងច្រើនសម្តែងឲ្យគេដឹង ចូលចិត្តរាប់អានតែជាមួយមនុស្សពាលឃោរឃៅសាហាវយង់ឃ្នងមិនត្រេកអរនឹងប្តីឬប្រពន្ធរបស់ខ្លួនបែរទៅងប់ងុលនឹងជនពេស្យា និងបំពានលើប្រពន្ធកូនអ្នកដទៃខ្លួនចាស់ហើយយកប្រពន្ធក្មេង ខ្លួនខ្សត់ទ្រព្យ

សម្បត្តិខ្សត់ចំណោះចំណោះប្រាជ្ញាហើយប្រាជ្ញាចង់ធ្វើធំ ជាដើម។

ផ្ទុយទៅវិញ អ្នកខ្លះធ្លាក់ខ្លួនជាអ្នកក្រ រងទុក្ខវេទនាដោយសារតែសង្គមអយុត្តិធម៌ ការជិះជាន់គាបសង្កត់ កេងប្រវ័ញ្ច ពុករលួយ បំបិទសិទ្ធិសេរីភាព ធ្វើទារុណកម្ម ពីសំណាក់មនុស្សនៅក្នុងវណ្ណៈជិជាន់ ដែលជាក្រុមមនុស្សពាលមានអំណាច អាជ្ញាធរខិលខូច និង អ្នកដឹកនាំស្ថាប័នចិត្តអាក្រក់ជាដើម។ ប្រសិនបើ អំពើថោកទាបរបស់មនុស្សដែលគ្មានគុណធម៌ របស់អ្នកមាន និងអ្នកមានអំណាច បន្តប្រព្រឹត្តអំពើអានាចារ្យគាបសង្កត់ បោកប្រាស់រាស្ត្រក្រីក្រតាមគ្រប់រូបភាព បំបិទសិទ្ធិប្រជារាស្ត្រ ពុករលួយ លួចប្លន់ទ្រព្យសម្បត្តិរាស្ត្រ និង ការបំបិទសិទ្ធិទទួលបានព័ត៌មាន នោះប្រជារាស្ត្រក្រីក្រលំបាកវេទនារស់នៅដូចប្រេតនៅឋាននរកលោកិយដែរ។នៅក្នុងមង្គលសូត្រ៣៨ប្រការ ត្រង់ប្រការទី៤ចែងថាការរស់នៅក្នុងប្រទេសដ៏សមគួរ ទើបមានមង្គលហេតុនេះប្រជាពលរដ្ឋ គួរតែនាំគ្នាត្រិះរិះពិចារណាគិតគូរដោះស្រាយបញ្ហាសង្គមនាពេលបច្ចុប្បន្នឱ្យបានល្អប្រសើរត្រឹមត្រូវ ដើម្បីផ្តល់ឱកាសដល់សមាជិកសង្គមទាំងអស់បានសាងជីវភាពរស់នៅកាន់តែមានយុត្តិធម៌ល្អប្រសើរប្រកបដោយសុភមង្គលនិងវិបុលភាព។ សម័យបច្ចុប្បន្ន ប្រទេសជាច្រើនបានជ្រើសរើសការដឹកនាំប្រទេសតាមលទ្ធិប្រជាធិបតេយ្យ ដើម្បីគោលដៅរស់នៅមាន សិទ្ធិ សេរីភាព ស្មើគ្នាចំពោះច្បាប់ប្រកបដោយយុត្តិធម៌ រីកចំរើន និងសុភមង្គល។

ពិភពលោកបច្ចុប្បន្នគឺជាយុគសម័យសាកលភាវូបនីយកម្មនៃវិទ្យាសាស្ត្របច្ចេកទេសដែលជំនឿសាសនាទាំងឡាយមិនមានឥទ្ធិពលខ្លាំងលើជីវភាពរស់នៅរបស់មនុស្សដូចសម័យបុរាណឡើយ។ យោងតាមទ្រឹស្តីវិទ្យាសាស្ត្រមនុស្សដែលស្លាប់គ្មានបន្សល់អ្វីដែលជាគ្រឿងសម្រាប់ចងចាំឡើយ សូម្បីព្រលឹងវិញ្ញាណក៏មិនអាចអត្ថិភាពបានឡើយ។ សូម្បីមនុស្សដែលនៅរស់ក៏អាចវង្វេង ឬមិនអាចចងចាំអ្វីបានដែរប្រសិនខួរក្បាលមានបញ្ហាវិបត្តិ ឬជម្ងឺជាដើម។ ចុះទម្រាំខ្មោចគ្មានរូបកាយខួរក្បាល តើព្រលឹងទៅជ្រកកោននៅឯណា? តើមានអ្វីជាមូលដ្ឋានត្រូវចងចាំបាន? តើមានអ្វីសម្រាប់ជាភស្តុតាងសម្រាប់ពន្យល់ពីនរកប្រេតបាន? ជំនឿជាតិមុខជាតិក្រោយ នរកប្រេត គឺជារឿងហួសនិស្ស័យ (អចិន្តយុង) សម្រាប់មនុស្សត្រិះរិះពិចារណាហេតុនេះយើងអាចបែរមករកការពិចារណាលើតថភាពសង្គមជាក់ស្តែងវិញ។ ចំពោះតថភាពជាក់ស្តែង ការបោះបាយបិណ្ឌមានប្រយោជន៍តិចតួចបំផុតសម្រាប់ចំណីអាហារដល់ប្រេត ឬសត្វតិរច្ឆាន ប៉ុន្តែគេក៏ពុំគួរមើលរំលងពីសារៈសំខាន់នៃជំនឿទំនៀមទម្លាប់ ប្រពៃណី ពិធីបុណ្យផ្សេងៗរបស់ជាតិនីមួយៗដែរ។

## ៦.អត្ថប្រយោជន៍នៃការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ

ដូចបានដឹងហើយថាអ្នកប្រាជ្ញខ្មែរមានគំនិតច្នៃប្រឌិតខ្ពស់ក្នុងការបង្កើតឱ្យមានកម្មវិធីបុណ្យភ្ជុំបិណ្ឌ។ ជាគោលការណ៍ វិធីបុណ្យភ្ជុំបិណ្ឌផ្តល់អត្ថប្រយោជន៍សម្រាប់សង្គមខ្មែរដូចតទៅ៖

ក.បង្ហាញថាខ្មែរជាពូជសាសន៍មានគុណធម៌ស្គាល់គុណ(កតញ្ញូតាធម៌)និងធ្វើតបគុណ(កតវេទិតាធម៌)ចំពោះបុព្វបុរសរបស់ខ្លួន។

ខ.បង្ហាញពីទស្សនៈស្តីពីជីវិតនិងការរស់នៅ ឬជំនឿស្តីអំពីទំនាក់ទំនងរវាងព្រលឹង និងរូបកាយ។ មកដល់សម័យទំនើបនេះ ខ្មែរភាគច្រើននៅតែជឿថា កាលណារូបកាយស្លាប់ ព្រលឹងមិនស្លាប់ទេនៅវិលកើតស្លាប់ជាអត្ថិភាពផ្សេងៗជាបន្តបន្ទាប់។ មនុស្សភាគច្រើននៅតែមានជំនឿលើភាវៈអរូបីថាមានឥទ្ធិពលលើការរស់នៅរបស់មនុស្ស។ ភាវៈអរូបីទាំងនោះមានដូចជា ខ្មោច ព្រាយ អារុក្ខអារក្ស អ្នកតា ទេវតា ប្រេត នរក និង សួគ៌ជាដើម។ ហេតុនេះទើគេបន្តអនុវត្តកិច្ចបូជាខាងសាសនាដោយផ្ទេរផ្តាច់រហូតមក។គេជឿថាមនុស្សដែលស្លាប់ទៅមិនមែនសុទ្ធតែចាប់កំណើតជាប្រេតទាំងអស់នោះទេ។ អ្នកធ្វើល្អតែងទៅកើតក្នុងសុគតិភពមានឋានទេវលោក ហើយអានិសង្ស(កុសលផលបុណ្យ) ដែលញាតិសន្តានឧទ្ទិសឱ្យក្នុងរដូវភ្ជុំបិណ្ឌក៏ទៅជួយសណ្តោងអ្នកល្អទាំងនោះឱ្យរីងរឹតសុខចំរើនទ្វេឡើងថែមទៀត។អ្នកធ្វើអាក្រក់តែងទៅកើតជាប្រេតក្នុងទុគតិភពមានឋាននរកជាដើម ហើយអានិសង្សកុសលផលបុណ្យដែលញាតិសន្តានឧទ្ទិសឱ្យក្នុងរដូវភ្ជុំបិណ្ឌអាចជួយឃឹតយោងប្រេតដែលជាអ្នកប្រព្រឹត្តិអាក្រក់ទាំងនោះ ឱ្យបានរួចចាកទុក្ខទោសបានមួយគ្រា។

គ. ជាឱកាសជួបជុំបងប្អូន កូនចៅ ញាតិមិត្តដែលបានឃ្លាតដោយសារការងារមុខរបរចិញ្ចឹមជីវិត។ ឱកាសនេះគេស្វែងស្កាត់រកគ្នា សួរសុខទុក្ខគ្នា ជជែកពិភាក្សាប្តូរទស្សនៈយោបល់គ្នា និង បរិភោគអាហារជុំគ្នាក្នុងភាពស្និទ្ធស្នាល[xv] និងភាតរភាព[xvi] ។

ឃ.ជាឱកាសសម្រាប់ឱ្យសមាជិកសង្គមអផ្សាស័យ[xvii] អភ័យទោស សន្តោសប្រោសប្រណី ស្រុះស្រួល និងសាមគ្គីគ្នាឡើងវិញបន្ទាប់ពីទទួលស្គាល់នូវកំហុសរបស់ខ្លួន។ ជារៀងរាល់ឆ្នាំ អ្នកដឹកនាំប្រទេសតែងមានការដោះលែងទណ្ឌិតមួយចំនួន ដែលអាចលើកលែងទោសបានទៅតាមស្ថានភាពជាក់ស្តែង ព្រោះពិចារណាឃើញថា ពុំមានអ្នកណាម្នាក់ឥតខ្ចោះរស់នៅដោយមិនប្រព្រឹត្តិនូវកំហុសឆ្គងឡើយ ហើយក៏គ្មាននរណាចង់រង់ទុក្ខទណ្ឌដែលមានកំណត់ក្នុងច្បាប់[xviii] ឡើយ។ ទោះបីច្បាប់ចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គមយ៉ាងណាក៏ដោយ ក៏មេដឹកនាំដែលឆ្លាតពូកែតែងតែពិនិត្យមើលលទ្ធភាពក្នុងការប្រើគុណធម៌សណ្តោសប្រោសប្រណី ដើម្បីលើកលែងទោសដល់អ្នកទោសមនសិការ ឬ

ជនជាប់ចោទ ឬជាប់ពិរុទ្ធពីរឿងនយោបាយជាដរាប ។

ង. រក្សាអត្តសញ្ញាណជាតិខ្មែរ ក្នុងការវេចនំគម នំអន្សម នំបត់ នំជាល ប្រចាំឆ្នាំ។ ពិធីបុណ្យភ្ជុំបិណ្ឌ គឺជារដូវនំគម នំអន្សមរបស់ខ្មែរ គេជូននំគ្នាបរិភោគទៅវិញទៅមកដែលជាប្រពៃណីទំនាក់ទំនងមិត្តភាពដ៏ប្រសើរ។ ជនជាតិខ្មែរយ៉ាងហោចណាស់ក៏បានភ្លក់រសជាតិនំអន្សមនៅរដូវបុណ្យភ្ជុំបិណ្ឌដែរ។ ពេលដល់រដូវភ្ជុំម្តងៗគេតែងនឹកឃើញនំអន្សម និងផ្ទុយមកវិញ។

ច.បន្ថយការលំបាកខ្លះដល់ព្រះសង្ឃ ក្នុងការស្វែងរកចង្ហាន់ទ្រទ្រង់ជីវិត ព្រោះថានៅរដូវវស្សា មេឃអួរអាប់ ភ្លៀងធ្លាក់បង្កឱ្យទឹកដក់ បែកភក់លើដី ដែលធ្វើឱ្យ ទទឹកទឹកភ្លៀង ឬប្រឡាក់ភក់ ឬរអិលដួល គ្រោះថ្នាក់ដល់ព្រះសង្ឃក្នុងការនិមន្តទ្រង់បាត្រ[xix]។ គេធ្វើពិធីបុណ្យភ្ជុំបិណ្ឌដើម្បីរៀបចំធ្វើសង្ឃភត្ត[xx] ទំនុកបម្រុងព្រះសង្ឃដែលគង់ចាំវស្សាក្នុងវត្ត។ កាលពីដំបូងគេធ្វើបុណ្យភ្ជុំបិណ្ឌរយៈពេល៣ខែ គឺចាប់តាំងពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ ក្រោយមកដោយសារប្រជាជនមានការលំបាក ខ្សត់ខ្សោយ ទើបបណ្តាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃបានត្រឹមតែ១៥ថ្ងៃវិញ។

ឆ.ជាឱកាសដែលខ្មែរគ្រប់រូប ក្មេងចាស់ ប្រុសស្រី បព្វជិតគ្រហស្ថ បានពិចារណាពីហេតុផលវិនាសនិងចំរើន តាមរយៈ បរាភវសូត្រ មង្គលសូត្រ ជាដើម។ អ្នកដែលប្រាថ្នារស់នៅក្នុងសុភមង្គល សេចក្តីសុខសួស្តី និងរីកចំរើន ត្រូវតែវៀចាកប្រធាននាំឲ្យវិនាស១២ប្រការដូចចែងក្នុងបរាភវសូត្រ និងរក្សាឲ្យបាននូវមង្គលទាំង៣៨ ដោយមិនចាំបាច់ធ្វើការសែនព្រេនបួងសួងបន់ស្រន់អ្វីឡើយ។

**៦.១. បរាភវសូត្រ (ប្រមុខនៃក្តីវិនាស)**

មាន១២ ប្រការគឺ៖ ១-បុគ្គលអ្នកទ្រុស្តធម៌ ស្អប់ធម៌ ២ -សេពគប់ជនពាល(អសប្បុរស) ៣ -កិរិយាដេក, និយាយ, ខ្ជិល, ខឹងច្រើន ៤-មិនចិញ្ចឹមមាតាបិតា ៥-ភូតកុហក បោកបញ្ឆោត ៦-លាក់អាហារឆ្ងាញ់ និង ធនធាន ៧-ប្រកាន់ជាតិ, ត្រកូល, ទ្រព្យ, ឋានៈ និងមិនរាប់សាច់ញាតិរបស់ខ្លួន ៨-ប្រព្រឹត្តល្បែង៣ប្រការ(ស្រី, ស្រា, ភ្នាល់) ៩-បុរសមិនត្រេកអរនឹងប្រពន្ធខ្លួន ១០-បុរសចាស់យកស្រីក្មេងធ្វើជាភរិយា ១១-ការជ្រើសរើសយកស្ត្រី ឬបុរសដែលជាមនុស្សខ្ជះខ្ជាយធ្វើជាគូកំណាន់ ១២-ជនកើតក្នុងត្រកូលក្សត្រខ្សត់ទ្រព្យប្រាថ្នាសោយរាជ្យ។

**៦.២.មង្គលសូត្រ ៣៨ ប្រការ៖**

១.កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ (អសេវនា ចពាលានំ)

២.កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ (បណ្ឌិតានញ្ច សេវនា)
៣.កិរិយាបូជាដល់បុគ្គលដែលគួរបូជា (បូជា ចបូជនីយានំ)
៤.កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ (បដិរូប ទេសវាសោច)
៥.ភាវៈនៃអ្នកបានធ្វើបុណ្យទុកហើយក្នុងកាល មុន ( បុព្វេ កតបុញ្ញតា)
៦.កិរិយាតម្កល់ខ្លួនទុកដោយប្រពៃ (អត្តសម្មា បណិធិ ច)
៧.ភាវៈជាបុគ្គលបានស្ដាប់បានរៀនសូត្រចេះ ដឹងច្រើន(ពាហុសច្ចំ)
៨.សេចក្តីឆ្លៀវឆ្លាតប៉ិនប្រសប់ក្នុងសិល្បៈទាំង ពួង ( សិប្បៈ)
៩.វិន័យដែលបុគ្គលបានសិក្សាហើយដោយ ប្រពៃ (វិនយោ ចសុសិក្ខិតោ)
១០.វាចាដែលបុគ្គលពោលដោយប្រពៃ ( សុភា សិតា ច យា វាចា)
១១.កិរិយាបម្រើ ឬ ទំនុកបម្រុងមាតា (មាតាបិតុ ឧបដ្ឋានំ)
១២.កិរិយាបម្រើ ឬ ទំនុកបម្រុងបិតា (មាតាបិតុ ឧបដ្ឋានំ)
១៣.កិរិយាសង្គ្រោះបុត្រ និងភរិយា (បុត្តទារស្ស សង្គហោ)
១៤.ការងារទាំងឡាយដែលមិនច្របូកច្របល់ (អនាកុលា ចកម្មន្តា)
១៥.កិរិយាបរិច្ចាគទាន(ទានំ)
១៦.កិរិយាប្រព្រឹត្តធម៌ដ៏ប្រសើរ(ធម្មចរិយា)
១៧.កិរិយាសង្គ្រោះញាតិទាំងឡាយ (ញាតិកា នញ្ច សង្គហោ)
១៨.កិរិយាប្រកបការងារទាំងឡាយដែលមិន មានទោស ( អនវជ្ជានិ កម្មានិ)
១៩.កិរិយាមិនត្រេកអរក្នុងបាបនិងកិរិយាវៀរ ចាកបាប(អារតី វិរតីបាបា)
២០.សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង (មជ្ជបានា ច សញ្ញមោ)
២១.ការមិនប្រមាទក្នុងធម៌ទាំងឡាយ (អប្បមា ទោ ចធម្មេសុ)
២២.កិរិយាគោរពចំពោះបុគ្គលដែលគួរគោរព( គារវោ ច)
២៣.កិរិយាប្រព្រឹត្តបន្ទាបខ្លួន(និវាតោ ច)
២៤.សេចក្តីសណ្តោសត្រេកអរចំពោះរបស់ដែល មាន (សន្តុដ្ឋី ច)
២៥.ភាពជាអ្នកដឹងឧបការគុណដែលអ្នកដទៃ ធ្វើហើយដល់ខ្លួន(កតញ្ញុតា)
២៦.កិរិយាស្តាប់នូវធម៌តាមកាល ( កាលេន ធម្ម ស្សវនំ)
២៧.សេចក្តីអត់ធ្មត់ (ខន្តិ ច)
២៨.ភាវៈនៃបុគ្គលដែលទូន្មានប្រៀនប្រដៅបាន ដោយងាយ (សោវចស្សតា)
២៩.កិរិយាបានឃើញ បានជួបនូវសាមណៈ ទាំងឡាយដែលមានឥន្ទ្រីយ៍ស្ងប់រំងាប់ហើយ (សមណានញ្ច ទស្សនំ)

៣០.កិរិយាសន្ទនាសាកសួរនូវធម៌តាមកាល (កាលេនធម្មសាកច្ឆា)

៣១.សេចក្តីព្យាយាមដុតនូវបាបធម៌ ( តបោ ច )

៣២.កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ (ព្រហ្មចរិយញ្ច)

៣៣.កិរិយាឃើញនូវអរិយសច្ចធម៌ទាំងឡាយ (បរិយសច្ចាន ទស្សនំ)

៣៤.កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដោយបញ្ញាដ៏ខ្ពង់ខ្ពស់ ( និព្វានសច្ឆិរិយា ច)

៣៥.ចិត្តនៃបុគ្គលដែលមិនញាប់ញ័រដោយលោកធម៌ (ផុដ្ឋស្ស លោកធម្មេហិចិត្តំយស្ស នកម្បតិ)

៣៦.ចិត្តនៃបុគ្គលមិនសោយសោកចំពោះអារម្មណ៍(អសោកំ)

៣៧.ចិត្តដ៏បរិសុទ្ធស្អាតចាកកិលេស(វិរជំ)

៣៨.ចិត្តក្សេមក្សាន្ត (ខេមំ)

## ៧.បញ្ហាប្រឈមមួយចំនួនក្នុងពេលអនុវត្តពិធីបុណ្យភ្ជុំបិណ្ឌ

ក្នុងករណីពិសេសដោយឡែក ដូចជានៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌ និងបុណ្យទាននានា ដែលគេចាត់ទុកជាពិធីមង្គល[xxi] បែរជាបានទទួលនូវអពមង្គល[xxii] ទៅវិញ ព្រោះធ្វើទៅមានការខាតបង់ធនធានទ្រព្យសម្បត្តិ ហើយអត្រាមនុស្សស្លាប់និងរបួសមានចំនួនច្រើន ដែលបានបន្សល់នូវសោកនាដកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គម ជាពិសេសនៅក្នុងរដូវបុណ្យទាននានា។ ដូច្នេះ ធ្វើអ្វី គួរតែកុំប្រមាទ[xxiii] និងប្រមាថ[xxiv] ។ គេសង្កេតឃើញថា រាល់ពិធីបុណ្យភ្ជុំបិណ្ឌ ក៏ដូចពិធីបុណ្យផ្សេងៗទៀតដែរ កម្ពុជានៅតែប្រឈមនឹងហានិភ័យកម្រិតខ្ពស់ជារៀងរាល់ឆ្នាំ ដូចជា៖

ក.បញ្ហាគ្រោះថ្នាក់ចរាចរណ៍ដោយសារប្រជាពលរដ្ឋជាច្រើននាំគ្នាសម្រុកទៅស្រុកកំណើតដើម្បីចូលរួមពិធីបុណ្យនិងដោយសារការប្រើប្រាស់គ្រឿងស្រវឹងលើសលប់។ អត្រាអ្នកស្លាប់និងរបួសបានបន្សល់នូវទុក្ខសោកសម្រាប់គ្រួសារនិងសង្គមជារៀងរាល់រដូវបុណ្យទានម្តងៗ។

ខ.ការអុជទៀនធូបមិនប្រយ័ត្នបណ្តាលឱ្យឆេះផ្ទះជារឿយៗ

គ.ការនាំគ្នាបិទទ្វារផ្ទះនៅទីក្រុង រួចធ្វើដំណើរទៅស្រុកកំណើតដោយមិនបានរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវបណ្តាលឱ្យមានបញ្ហាផ្ទុះខ្សែភ្លើង ឬផ្ទះធ្លាយទុយោទឹក ឬមានបញ្ហាចោរកម្ម ការលួចគាស់ផ្ទះជាដើម។

ឃ.ការឆ្លៀតឱកាសតម្លើងថ្លៃទំនិញសព្វសារពើសេវាកម្មដឹកជញ្ជូនឡើងថ្លៃហួសប្រមាណពីជនឱកាសនិយម។

ង.ការខ្វះការសន្សំសំចៃ ដោយចំណាយខ្ជះខ្ជាយក្នុងកម្មវិធីបុណ្យធ្វើឱ្យជីវភាពនៅតែក្រីក្រ ព្រោះរកស៊ីឬធ្វើការងារពេញមួយឆ្នាំសម្រាប់ចាយតែមួយកម្មវិធី ដោយគេពោលថា មួយឆ្នាំមានម្តងកុំគិតច្រើន។

ច.ការបោះបាយបិណ្ឌពាសវាលពាសកាល គ្មាន សណ្ដាប់ធ្នាប់ នាំឱ្យខូចបរិស្ថាន បាត់ភាពថ្លៃថ្នូរ។

ឆ.ការសំរុកយកទេយ្យទាន មាននិចំណីទៅប្រគេនព្រះសង្ឃក្នុងពេលតែមួយ ធ្វើឱ្យចាក់គរចោលខូចគុណភាព។ ជាធម្មតា នៅថ្ងៃធម្មតាក្រៅពីមាននកម្មវិធីបុណ្យ ព្រះសង្ឃមានការខ្វះខាតចង្ហាន់និងសម្ភារៈជារឿយៗ។

## ៨. ដំណោះស្រាយបញ្ហា

ដូចបានដឹងរួចហើយថា រាល់ពិធីបុណ្យភ្ជុំបិណ្ឌ ក៏ដូចពិធីបុណ្យផ្សេងៗកម្ពុជាតែងប្រឈមនឹងគ្រោះថ្នាក់ចរាចរណ៍ ឆេះផ្ទះ ផ្ទុះខ្សែភ្លើង ផ្ទុះធ្លាយទុយោទឹក មានបញ្ហាចោរកម្ម ទំនិញសេវាកម្មដឹកជញ្ជូនឡើងថ្លៃហួសប្រមាណ បរិស្ថានកខ្វក់ ជីវភាពនៅតែក្រីក្រ ការខ្ជះខ្ជាយព្រះសង្ឃសំបូរចាក់គរចោលខ្វះខាតចង្ហាន់ពេញមួយឆ្នាំ។ យើងគួរមានដំណោះស្រាយខ្លះដូចតទៅ៖

ក.ស្ថាប័នរដ្ឋដើរតួសំខាន់ក្នុងការទទួលខុសត្រូវលើគុណភាពនិងទំហំផ្លូវទាំងឡាយទូទាំងប្រទេស និងផាកពិន័យចំពោះអ្នកគ្មានប័ណ្ណបើកបរយានយន្ត និង អ្នកបើកបរដោយឥទ្ធិពលនៃជាតិស្រវឹង។

ខ.កាត់បន្ថយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនដោយងាកទៅរកមធ្យោបាយរួមដែលមានការទទួលខុសត្រូវ និង ឧបត្ថម្ភ ពីស្ថាប័នរដ្ឋ

គ.គ្រប់គ្រង និងដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាពត្រឹមត្រូវនូវរចនាសម្ព័ន្ធ និងប្រពន្ធដឹកជញ្ជូនគ្រប់ប្រភេទ

ឃ.ត្រូវមានវិធានការណ៍ច្បាស់លាស់ចំពោះឈ្មួញទុច្ចរិតដែលឆ្លៀតតម្លើងថ្លៃ ធ្វើដំណើរនៅរដូវបុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យប្រពៃណីប្រចាំឆ្នាំដទៃទៀត។

ង.ពលរដ្ឋម្នាក់ៗត្រូវមានស្មារតីប្រុងប្រយ័ត្នជានិច្ច មុនចេញដំណើរចាកចេញពីផ្ទះ ដោយត្រូវពិនិត្យពិច័យ ភ្លើងទៀន ធូប ប្រព័ន្ធភ្លើងអគ្គីសនី ប្រព័ន្ធទឹកឱ្យបានត្រឹមត្រូវ។

ច.អាជ្ញាធរមានសមត្ថកិច្ច និង ពលរដ្ឋម្នាក់ៗត្រូវតែយកចិត្តទុកដាក់អំពីសន្តិសុខ សណ្ដាប់ធ្នាប់ អនាម័យ និងរក្សាទ្រព្យសម្បត្តិឱ្យបានជាប្រចាំ។

ឆ.ត្រូវកាត់បន្ថយ ការស៊ីផឹកគ្រឿងស្រវឹង និងបង្ក្រាបឱបាននូវល្បែងស៊ីសងគ្រប់ប្រភេទ។

ជ.ព្រះសង្ឃគួរទេសនាឱ្យបានត្រឹមត្រូវតាមទ្រឹស្ដីព្រះពុទ្ធ អំពីអានិសង្សបុណ្យ ដើម្បីឱ្យប្រជាជនយល់ដឹងក្នុងការបរិច្ចាគទានប្រកបដោយវិចារណញ្ញាណ ចៀសវាងការធ្វើទានដោយសទ្ធាងងឹតងងុលខ្វះបញ្ញា។

ឈ.ប្រើពិធីបុណ្យនេះ ជាឱកាសពិចារណាស្វែងយល់ដឹង និង អនុវត្តនូវ ពុទ្ធភាសិតទាំងឡាយ ដូចជា មង្គលសូត្រ និង បរាភវសូត្រ ព្រមទាំងបទសូត្រ និង បទចម្រៀងផ្សេងទៀតដែលទាក់ទងនឹងប្រពៃណីបុណ្យភ្ជុំ ដែលអ្នកប្រាជ្ញ

*កវីខ្មែរនិពន្ធឡើងនាសម័យទំនើបបច្ចុប្បន្ន ដូចជា បទស្មូត្រទំនួញប្រេត បទចម្រៀងទៅភ្ជុំបិណ្ឌទៅលេងស្រុក។ល។*

## ៩. សេចក្ដីសន្និដ្ឋាន

*ពិធីបុណ្យភ្ជុំបិណ្ឌមិនត្រឹមតែជាកាលវេលាដ៏មានអត្ថន័យសម្រាប់តែពុទ្ធសាសនិកជនក្នុងការបំពេញកិច្ចជាពិធីកម្មតាមពុទ្ធបញ្ញត្តិប៉ុណ្ណោះទេប៉ុន្តែវាជាឱកាសដ៏មានសារៈសំខាន់មួយសម្រាប់ពលរដ្ឋខ្មែរទូទៅទូទាំងពិភពលោកមានឱកាសបានជួបជុំទំនាក់ទំនងល្អរវាងមនុស្សនិងមនុស្ស ព្រមទាំងរវាងមនុស្សនិងអមនុស្សពោលគឺជាការរួបរួមប្រជុំប្រកបដោយព្រហ្មវិហារធម៌រវាងអ្នកមិនទាន់ស្លាប់និងអ្នកស្លាប់។ ពិធីបុណ្យភ្ជុំបិណ្ឌ បានផ្ដល់អត្ថប្រយោជន៍ច្រើនសម្រាប់សង្គមខ្មែរ ព្រោះជាឱកាសសម្រាប់ពិចារណាពីហេតុនៃវិនាសនិងចំរើន ជាឱកាសអហោសិកម្មលើកលែងអ្នកមានទោសដឹងកំហុស ជាឱកាសរំលឹកពីតម្លៃអត្តសញ្ញាណជាតិខ្មែរតាមរយៈ នំគម នំអន្សមជាដើម។ ប៉ុន្តែគួរកត់សម្គាល់ផងដែរ ដោយសាររៀងរាល់ពិធីបុណ្យភ្ជុំបិណ្ឌក៏ដូចជាពិធីបុណ្យផ្សេងៗដែរ សង្គមកម្ពុជាតែងប្រឈមខ្លាំងចំពោះគ្រោះថ្នាក់ចរាចរណ៍ ចោរកម្ម អគ្គីភ័យ និងទំនិញសេវាកម្មដឹកជញ្ជូនឡើងថ្លៃហួសប្រមាណ។ លើសពីនេះពិធីនេះហាក់បង្ហាញពីភាពខ្វះខាតរបស់ពលរដ្ឋមួយចំនួនក្នុងខណៈពេលដែលជីវភាពខ្លួនស្ថិតក្នុងសភាពគ្រីក្រជំពាក់បំណុលរុំកោះ។ រយៈពេលថ្ងៃបុណ្យចង្ហាន់ព្រះសង្ឃសម្បូរពេញពាសបន្ទាប់មកអត្តខាត់បន្តពេញមួយឆ្នាំ។ បញ្ហាទាំងនេះអាចចាត់វិធានការណ៍ដោះស្រាយប្រកបដោយប្រសិទ្ធភាពប្រសិនបើពលរដ្ឋគ្រប់រូបមានមនសិការភ្ញាក់រលឹកប្រកបដោយសុភវិច្ឆ័យ។ ផ្អែកមនសិការភ្ញាក់រលឹកនិងដោយឈរលើឧត្តមគតិជាតិពលរដ្ឋខ្មែរអាចរំដោះខ្លួនចេញពីភាពអាត្មានិយម អួតអាងស៊ីបញ្ចោរ ឱ្យងាកបែរមករកត្រិះរិះពិចារណាសាងប្រយោជន៍រួមសម្រាប់ជោគវាសនាខ្លួននិងមនុស្សជំនាន់ក្រោយបាន។ ដើម្បីចៀសផុតពីបញ្ហាដដែលៗ សង្គមខ្មែរទាំងមូលត្រូវចេះលើកទឹកចិត្តគ្នាឱ្យសន្សំសំចៃថ្នែប្រឹតខ្ពស់ឱ្យចូលចិត្តប្រើប្រាស់មធ្យោបាយធ្វើដំណើររួមគ្នា និងកសាងឱ្យស្របតាមលក្ខណៈបច្ចេកទេសនូវរចនាសម្ព័ន្ធផ្លូវនិងប្រពន្ធដឹកជញ្ជូនគ្រប់ប្រភេទ ថែមទាំងនាំគ្នាថែរក្សាការពារសមិទ្ធផលទាំងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។ ប្រើប្រាស់ពុទ្ធភាសិតដូចដែលមានចែងក្នុងមង្គលសូត្រនិងបរាភវសូត្រ ដើម្បីធ្វើជាយន្តការដើម្បីបំបាត់ការសេពគ្រឿងស្រវឹងការលេងល្បែងស៊ីសង ការជឿអបិយជំនឿដោយងងឹតងុលខ្វះការពិចារណា។ ទន្ទឹមនឹងនេះ គ្រប់គ្នាត្រូវបង្កើនការប្រុងប្រយ័ត្នចំពោះភ្លើងទៀនធូបប្រព័ន្ធភ្លើងអគ្គីសនី ប្រព័ន្ធទឹក សន្តិសុខសណ្ដាប់ធ្នាប់ អនាម័យ រក្សាទ្រព្យសម្បត្តិ និងត្រូវចាត់វិធានការណ៍ច្បាស់លាស់ចំពោះជន*

ទុច្ចរិត និង ជនពុករលួយដែលគប់គិតគ្នាឆ្មៀតតម្មើងថ្លៃលើមធ្យោបាយធ្វើដំណើរនៅរដូវបុណ្យទាន។លើសពីនេះគេគួរតែមានសេចក្ដីក្លាហានបំបាត់ជំនឿណាដែលគ្មានប្រយោជន៍ខ្វះសច្ចភាពដែលអាចនាំមនុស្សខ្មែរឱ្យធ្លាក់ក្នុងភាពល្ងង់ខ្លៅវង្វេងស្គាល់ការពិតមិនច្បាស់លាស់ហើយរស់នៅឃ្លាតឆ្ងាយពីសម័យកាលវិទ្យាសាស្ត្របច្ចេកទេស និង ប្រាសចាកសីលធម៌ដែលនាំឱ្យមានគ្រោះថ្នាក់ដល់ខ្លួន គ្រួសារ និង សង្គមទាំងមូលបាន។ គេអាចបន្ថយឬឈប់បោះបាយបិណ្ឌចោលពាសវាលពាសកាលរាយប៉ាយពេញវត្តអារាម ព្រោះវាក្លាយជាសម្រាមស្អុយកខ្វក់ និងជាការបង្ហាញគំនិតខ្ជះខ្ជាយ ខ្វះសណ្ដាប់ធ្នាប់ និងបាត់ភាពថ្លៃថ្នូរនៃពូជសាសន៍ខ្មែរផងដែរ។ បន្ថែមលើនេះ យើងគួរបរិច្ចាកធនធានឱ្យបានត្រឹមត្រូវដោយមិនគួរខ្ជះខ្ជាយឡើយ។ ការប្រគេនទេយ្យទានដល់ព្រះសង្ឃក៏គួរចេះលៃលកដាក់ទានដល់អ្នកក្រីក្រផង ហើយមិនគួរប្រកាន់ធ្វើតែក្នុងរដូវបុណ្យភ្ជុំបិណ្ឌ ឬបុណ្យទានផ្សេងៗនោះឡើយ គឺគួរធ្វើនៅក្នុងជីវភាពប្រចាំថ្ងៃផងដែរ។ ខ្មែរត្រូវចពង្រឹងវប្បធម៌ចែករំលែកទាំងទ្រព្យសម្បត្តិនិងចំណេះដឹង គឺអ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ដើម្បីរក្សាទំនាក់ទំនងល្អរវាងអ្នកមាននិងអ្នកក្រ រវាងអ្នកប្រាជ្ញនិងអ្នកល្ងង់ក្នុងគោលដៅកាត់បន្ថយគម្លាតឆ្ងាយរវាងអ្នកមាននឹងអ្នកក្រ បំបាត់ការរើសអើងរវាងអ្នកចេះដឹងនិងអ្នកល្ងង់ ឈានទៅសម្រេចគោលបំណងរួមរស់នៅក្នុងភាពសុខដុមរមនាតកូនចៅជានិរន្តរ៍តទៅ។

## គន្ថនិទ្ទេស


១.ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី ៥, ឆ្នាំ១៩៦៧

២. ត្រឹង ងា *អរិយធម៌ខ្មែរ* ភ្នំពេញ បោះពុម្ពឆ្នាំ ១៩៧៤

៣.ពុទ្ធសាសនបណ្ឌិត្យ, *ព្រះត្រៃបិដក* ភ្នំពេញ ព.ស.២៤៩៧

៤. ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)

៥.*វិទ្យុអាស៊ីសេរី*, https://www.rfa.org

៦.*វិទ្យុបារាំងអន្តរជាតិជាភាសាខ្មែរ*, https://www.rfi.fr/km


---

[i] ជាតិសាសន៍នានាដែល ប្រារព្ធពិធីបុណ្យស្រដៀងនឹងបុណ្យភ្ជុំបិណ្ឌខ្មែរមានដូចជា៖ ១.អាមេរិក និង អឺរ៉ុបប្រារព្ធពិធីបុណ្យ Halloween នៅរាល់ថ្ងៃទី ៣១ ខែតុលា, ២. ជប៉ុន មានបុណ្យ Obon ធ្វើរៀងរាល់ថ្ងៃទី ១៥ ខែទី៧ នៃចន្ទគតិ (ត្រូវនឹងខែកក្កដា ឬសីហា), ៣. មិកស៊ិក អាមេរិកឡាទីន ធ្វើបុណ្យ Dia de los Muertos រៀងរាល់ថ្ងៃទី១ និងទី២ ខែវិច្ឆិកា, ៤.កូរ៉េទាំងពីរ ធ្វើបុណ្យ Chuseok រាល់ខែទី

៨ នៃប្រតិទិនចន្ទគតិ (ខែកញ្ញា ឬតុលា), ៥.នេប៉ាល់ ធ្វើបុណ្យ Gai Jatra រៀងរាល់ខែសីហា ឬកញ្ញា, ៦.ចិន និងបណ្តាប្រទេសមួយចំនួន ធ្វើបុណ្យសែនក្បាលទឹក រៀងរាល់ថ្ងៃទី១៥ ខែទី៧ នៃចន្ទគតិ (ខែកក្កដា ឬសីហា)។

ii អបាយភូមិ គឺជាទីដែលមានសេចក្តីវិនាសប្រាសចាកសេចក្តីចម្រើន, ទីរងទុក្ខមានឋាននរកជាដើម។

iii ប្រសើរនៅទីនេះ មានន័យថា ល្អ និង ត្រឹមត្រូវ។ ល្អ គឺ អ្វីដែលមនុស្សទូទៅពេញចិត្ត រីឯ ត្រឹមត្រូវ គឺអ្វីដែលស្របតាមក្រឹត្យក្រមធម្មជាតិ ។

iv សីល៥ គឺការប្រព្រឹត្តល្អដោយកាយវាចា ដោយមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ៥ប្រការគឺៈ ១.មិនសម្លាប់ ២.មិនលួច ៣.មិនកុហក ៤.មិនផិតក្បត់ ៥.មិនសេពគ្រឿងញៀនស្រវឹង។

v សីល៨ គឺសីលដែលជម្រះដល់ចិត្ត (ឬឧបោសថសីល) ឬការប្រព្រឹត្តល្អដោយកាយ វាចា និងចិត្ត ដោយមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ៥ប្រការ (សីល៥) បូករួមនឹង៣ប្រការថែមទៀតគឺៈ ១.មិនទទួលទានអាហារខុសកាលវេលា ២.មិនសំអិតសំអាងកាយដោយអលង្ការនិងគ្រឿងក្រអូប ៣.មិនដេកនៅកន្លែងប្រណីត។

vi បាយបាត្រ (ន.) គឺជាបាយដែលគេដាក់ ជាភាជនៈមានរាងជ្រៅក្រឡូមសម្រាប់បព្វជិតប្រើការទទួលចង្ហាន់។ ទស្សនៈខ្មែរមួយពោលថា ធ្វើអ្វីឱ្យច្បាស់លាស់កុំឱ្យ ច្របូកច្របល់ បាយបិណ្ឌទៅជាបាយបាត្រ ព្រោះបាយបិណ្ឌសម្រាប់ប្រេត បាយបាត្រសម្រាប់មនុស្ស។

vii នមស្ការព្រះរត្នត្រ័យ គឺកិរិយាបង្អោនកាយថ្វាយបង្គំក្រាបប្រណិប័តៈ គំនាប់ចំពោះព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ។

viii សមាទានសីល (សៈម៉ាទៀនសិល) បញ្ចេញវាចាប្តេជ្ញាទទួលកាន់តាមឬប្រព្រឹត្តល្អដោយកាយវាចា, វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ។

ix បរិត្ត (ប៉ៈរិត) ធម៌សម្រាប់ការពារសេចក្តីអន្តរាយ ។

x ប៉ុន្តែមានវត្តខ្លះ ពេលខ្លះមិនអនុញ្ញាតិឱ្យមានការបោះបាយបិណ្ឌទេអាស្រ័យទៅតាមការកំណត់របស់ព្រះសង្ឃនិងគណៈកម្មការវត្តទាំងនោះ។

xi បង្សុកូល(ប័ង-សុកូល) សំពត់ដែលគេចោលលើគំនរសំរាមជាដើម ប្រឡាក់សៅហ្មងដោយអាចម៍ដី, ដោយធូលីដែលបព្វជិតក្នុងពុទ្ធសាសនាទស់ដោយសម្គាល់ថាជារបស់ឥតម្ចាស់ ព្រោះគេបោះបង់ចោល លែងត្រូវការហើយទាញយកមកផ្សែផ្សំធ្វើជាចីវរប្រើប្រាស់តាមពុទ្ធានុញ្ញាត (ចំពោះតែសំពត់មានព័ណ៌សឬលឿង ដែលល្មមយកមកជ្រលក់សម្រួលព័ណ៌បាន; រាប់ថាជាសំពត់ថ្លៃថ្លាវិសេសសម្រាប់បព្វជិតអ្នកមានសន្តោសស្ងប់រម្ងាប់) ។ លុះដល់មកក្នុងសម័យសព្វថ្ងៃនេះ សូម្បីសំពត់ដែលទាយកគេពាក់ឬគ្របលើក្តារមឈូសជាដើម គេនិមន្តឱ្យបព្វជិតទាញយកទៅទីចំពោះមុខគេ ឬកំបាំងពីមុខគេក៏ហៅសំពត់បង្សុកូលដែរ។ ខ្មែរយើងប្រើតាមទម្លាប់ប្រទេសហៅដំណើរដែលគេនិមន្តភិក្ខុសាមណេរឲ្យចាប់កាន់អំបោះឬផ្ទាំងសំពត់ដែលតភ្ជាប់ពីសាកសពឬពីអដ្ឋិធាតុមកសូត្រធម៌ អនិច្ចាវត សង្ខារា...ក៏ហៅ បង្សុកូលដែរ។

[xii] ថ្វាយព្រះបិតរ ឬ ថ្វាយព្រះបិដរ ជាឈ្មោះព្រះរាជពិធីមួយមានចាក់ទឹកដូងច្រួចសែនរំឭកដល់ពួកបុព្វបុរសក្នុងរាជត្រកូល គឺសែនរំឭកទៅព្រះញាតិវង្សានុវង្សដែលស្តេចទៅកាន់បរលោកហើយ ។

[xiii] គាថាពាន់ គឺ គាថាបាលីចំនួនមួយពាន់ ក្នុងមហាវេស្សន្តរជាតក (មហាជាតក៏) ដែលលោកអ្នកប្រាជ្ញខ្មែរបានដកស្រង់ពីក្នុងគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ ចារជាគម្ពីរស្លឹករឹត(គាថាបាលីសុទ្ធ) សម្រាប់ទេសនាអានបាលីសុទ្ធប្រើការអានជាបទសរភញ្ញខ្លីៗ តាមសង្កាត់បាទនៃគាថាដែលមាន១៣កណ្ឌ ។

[xiv] តិរោកុឌ្ឌសូត្រ ហៅដោយខ្លីតាមទម្លាប់ស្រួលមាត់ត្រឹមតែ តិរោក ក៏បាន។ ក្នុងប្រទេសខ្មែរយើង ប្រើធម៌នេះសម្រាប់សូត្រជារឧទ្ទិសចំណែកបុណ្យជូនទៅបុព្វបេតបុគ្គលដែលចែកឋានទៅកាន់បរលោកហើយ។

[xv] ស្និទ្ធស្នាល គឺជិតដិតនឹងគ្នាឥតរង្កៀស។ សេចក្តីស្និទ្ធស្នាល មានរសត្រកាល ប្រសើរថ្លៃថ្លា ជាងអស់រសផង ដែលឆ្ងាញ់ពីសា ឥតមានភោជនណា ប្រដូចស្មើបាន។ ដ្បិតរសភោជន ទោះឆ្ងាញ់ពេកពន់ចិញ្ចឹមរូបប្រាណ ឆ្ងាញ់តែមួយពេល ពុំយូរប៉ុន្មានស្និទ្ធស្នាលឆ្ងាញ់បាន អស់កាលយូរលង់ ។

[xvi] ភាតរភាព(ភាត់រ៉ៈភាប) សេចក្តីរាប់រកគ្នាដូចបងដូចប្អូន។

[xvii] អជ្ឈាស័យ ( អ័ច-ឈាសៃ) (ច្រើនប្រើ អធ្យាស្រ័យ) គឺសភាវៈដែលដេកអាស្រ័យនៅក្នុងចិត្ត មានន័យថា ការពិចារណារកហេតុផល ត្រូវឬខុស ល្អឬអាក្រក់។ ខ្ញុំសូមអធ្យាស្រ័យ មានន័យថា ខ្ញុំគិតថាខ្ញុំអាចធ្វើខុសមិនល្អ។

[xviii] ច្បាប់ជាសេចក្តីបញ្ញត្តិសម្រាប់ឲ្យអ្នកនគរប្រតិបត្តិតាមដើម្បីសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខសង្គម។ ជាធម្មតាស្មារតីច្បាប់គឺដើម្បីការពារផលប្រយោជន៍ក្រុម ឬបក្សណាមួយដែលមានឥទ្ធិពលខ្លាំង ហេតុនេះជាយថាហេតុវាតែងតែខាតប្រយោជន៍ក្រុមណាមួយដោយចៀសមិនរួច។ គោលបំណងនៃច្បាប់ គឺដើម្បីយុត្តិធម៌ ប៉ុន្តែចៀសមិនផុតពីអយុត្តិធម៌ឡើយ។ ប្លាតុង ពោលថា នៅទីណាក៏មានច្បាប់ដែរ ប៉ុន្តែសម្រាប់តែអ្នកឈ្នះប៉ុណ្ណោះ។ ចំណែក សូក្រាត ពោលថា មានតែច្បាប់អាទិទេពទេ ទើបមានយុត្តិធម៌។ ជាទូទៅច្បាប់មានសារៈសំខាន់ចាំបាច់សម្រាប់សង្គមមនុស្ស ប៉ុន្តែក្នុងការអនុវត្តវាមិនគ្រប់គ្រាន់ឡើយពេលខ្លះវាមានភាពទាល់ច្រក ហេតុនេះមានគេត្រូវប្រើគុណធម៌ដើម្បីដោះស្រាយ។ ពេលខ្លះច្បាប់មានភាពអមនុស្សធម៌ ហេតុនេះហើយ ទើបចាំបាច់ត្រូវតែប្រើគុណធម៌។ ខុង ជឺ ពោលថា ការគ្រប់គ្រងដោយគុណធម៌ ប្រសើរជាងគ្រប់គ្រងដោយច្បាប់។

[xix] ទ្រង់បាត្រ (ឬបិណ្ឌបាត) ដើរទទួលយកដុំបាយឬចង្ហាន់ដែលអ្នកស្រុកមានសទ្ធាប្រគេនឬរាប់បាត្រ។

[xx] សង្ឃភត្ត(សង់ ឃៈ ភ័ត) បាយ អាហារសម្រាប់ព្រះសង្ឃ ។

[xxi] ពិធីមង្គល ជាការរៀបចំរណ្តាប់ កិច្ចផ្សេងៗដោយការបួងសួង សុំឱ្យមានស្រីសួស្តី។

[xxii] អពមង្គល ជាការប្រាសចាកសិរីសួស្តី, ឃ្លាងផុតពីមង្គល, ហេតុដែលនាំឲ្យវិនាសអាប់ឱន។ ហេតុឬអំពើណាដែលនាំឲ្យវិនាសបើទុកជាសន្មតឬជឿ

ថាជាមង្គល ក៏គង់នៅជាអពមង្គលតាមធម្មតា ដូច្នោះឯង, យើងទាំងអស់គ្នាសុទ្ធតែជាអ្នកត្រូវការដោយមង្គល ប៉ុន្តែប្រយ័ត្ន ក្រែងលោភ័ន្តច្រឡំលើអពមង្គលទៅវិញ។

[xxiii] ប្រមាទ (ប្រម៉ាត) ជាការភ្លេចស្មារតី, ធ្វេសស្មារតី, សេចក្តីប្រហែស, ការប្រហែសធ្វេស ។

[xxiv] ប្រមាថ (ប្រម៉ាត) ជាការបៀតបៀនគេ, ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឲ្យគេលំបាក; ការមើលងាយគេ ។